# ការសំភាសន៍ជាលើកទី២របស់លោកយាយ គឹម លន់ ហៅគឹម សំបូរ

កៈ អ្នកដែលសំភាសន៍ ញ៉ែម សុគន្ធា ខៈ អ្នកដែលត្រូវគេសំភាសន៍ឈ្មោះគឹម លន់

## <u>ការសង្ខេបរបស់លោកយាយ គឹម លន់ ហៅគឹម សំបូរ</u>

លោកយាយគឹម លន់ គាត់បានជួបរឿងជាច្រើននៅក្នុងជីវិត លោកយាយបានត្រូវស្នាមពេញខ្លួនដោយសារតែសម័យសង្គ្រាមទំលាក់គ្រាប់បែកហើយកូន ២នាក់ត្រូវបានស្លាប់ នេះជាទុក្ខលំបាកដែលពិបាកទទួលយក ហើយចូលមកក្នុងរបបប៉ុល ពតទៀត

គាត់ត្រូវបានគេហៅអោយគាត់ធ្វើជាជាងដេរដោយសារគេដឹងថាគាត់ចេះដេរហើយបើគ្មានអ្វីដេរគេអោយគាត់ទៅធ្វើការស្ទូងដកគឺពួកប៉ុលពតមិនអោយគាត់ទំនេរតែម្តង!!ហើយនៅពេលថ្ងៃមួយគឺស្វាមីគាត់បានទៅលួចបូតស្រូវគេដោយសារអត់ឃ្លានពេក ហើយគេបំរុងយកទៅសម្លាប់ចោលប៉ុន្តែទទួលទាបានរៀតណាមមកទាន់ក៏រួចខ្លួន។ ឥឡូវលោកយាយរស់នៅជាមួយកូនហើយស្វាមីបានទៅបួសនៅឯកំពង់ទៅ។

កៈ

ជាដំបូងនាងខ្ញុំសូមថ្លែងអំណរគុណដល់លោកយាយដើម្បីអោយញ៉ុមសំភាសន៍អំពីជីវប្រវត្តិរបស់លោកយាយម្តងទៀត នាងខ្ញុំឈ្មោះញ៉ែម សុគន្ធា ជាអ្នកសំភាសន៍អំពីជីវប្រវត្តិរបស់លោកយាយនៅក្នុងថ្ងៃនេះ។ ពួកយើងសំភាសន៍នៅក្នុងភូមិព្រៃកហូរខាងលិច សង្កាត់ព្រៃកហូរ ក្រុងតាខ្មៅ ខេត្តកណ្តាល ប្រទេសកម្ពុជា អ៊ិចឹងពួកយើងសំភាសន៍នៅក្នុងខែមិនា ឆ្នាំ២០១៨!! ដោយសារពេលមុនពួកយើងបាននិយាយខ្លះៗអំពីជីវប្រវត្តិរបស់លោកយាយអំពីដូនតាខ្លះៗ ហើយអញ្ចឹងពួកយើងនឹងនិយាយអំពីសំនួរផ្សេងៗទៀតដើម្បីសួរដល់លោកយាយដើម្បីប្រាប់អំពីសម័យដែលលោកយាយជួបនឹងរឿងខ្មោងងឹតនៅក្នុងប្រវត្តិសង្គ្រាមហ្នឹងលោកយាយហាំ!!

ខៈចាំ!!

កៈ អញ្ចឹងលោកយាយសូមប្រាប់ឈ្មោះពេញលោកយាយម្តងទៀតមក?

ខ៖ ញ៉ុមកាលទៅអាពតហ្នឹងគេហៅញ៉ុមតែលន់ តែលន់ហ្នឹងព្រោះយើងទៅ
ទៅស្រុកកំណើតឪពុកញ៉ុមហ្នឹងគេស្គាល់តែឈ្មោះលន់ ហ្នឹងទេ!!

ក៖ ចាំ!!ហើយដល់ពេលពេលមុនបានឈ្មោះសំបូរ!!

ខ៖ សំបូរ!!ចាំ!!

ក៖ គឹម សំបូរ តែដល់ពេលឥឡូវគឹម លន់ ។

ខ៖ ពេលនៅកោះកុងគេហៅយើង ធ្វើការធ្វើអីនៅណោះ
ហើយដល់ពេលស្រុកកំណើតនេះអត់ស្គាល់គេហៅតែយាយលន់
យាយលន់ហ្នឹងទៅ!!ហៅតែលន់ លន់ ហ្នឹងទៅ
ក៏ដាក់យាយលន់ហ្នឹងទៅ!!ព្រោះអីយើងអស់មានការងារអីធ្វើទៀតហើយ!!

ក៖ចាំ!!

ខ៖ ចាំ!!

ក៖ អញ្ចឹងលោកយាយសំរាប់ចូលដល់ការសិក្សារបស់លោកយាយហាំ
លោកយាយរៀនបានថ្នាក់ទីប៉ុន្មានដែរ?

ខ៖ ញ៉ុមពីដើមថ្នាក់ទី៧។

ក៖ ថ្នាក់ទី៧បានពាក់កណ្ដាលហើយយាយ?

ខ៖ ពាក់កណ្ដាលហាហើយ!!

ក៖ ពេលហ្នឹងរាប់ពីបញ្រ្ចាស់មកវិញហេលោកយាយ?

ខ៖ ចាំគេរាប់ពី១២មកវិញ។

ក៖ ចាំ មើល! ១២ ១១ ១០ ៩ ៨ ៧ អ៊ីចឹងបានថ្នាក់ទី៦ដែរលោកយាយណោះ?

ខ៖ ចាំ!!

ក៖ លោកយាយពេលរៀនហ្នឹងរៀននៅសាលាបឋមសិក្សាណាវិញ?

ខ៖ ញ៉ុមរៀនពីដំបូងញ៉ុមរៀន
កាលពីដំបូងញ៉ុមអត់ទាន់មកទិញដីនៅកំពង់សំណាញ់កន្លែងដីចាស់ហ្នឹង ។

ក៖ចាំ!!

ខ៖ ឪពុកញ៉ុមគាត់នៅខាងបឹងត្របែក។

ក៖ នៅភ្នំពេញណោះវិញ?

ខ៖ ចាំ!!រៀននៅសាលាបឹងត្របែក!!

ក៖ ហ្ហ៎អ៊ីចឹងសាលាដែលលោកយាយរៀនហ្នឹងនៅសាលាបឹងត្របែកទេអញ្ចឹងហោ?

ខ៖ ចាំ!!!ដល់ពេលទៅនៅកោះកុងបានចូលរៀននៅកោះកុងវិញ។

ក៖ ចាំសុទ្ធតែបឋមសិក្សាទាំងអស់ហោ?

ខ៖ចាំ!!

ក៖ ចាំអ៊ីចឹងសាលាកោះកុងនៅណោះឈ្មោះសាលាអីគេវិញទៅលោកយាយ?

ខ៖ នៅណោះ មិនដឹងសាលាអីគេទេនេះភ្លេចបាត់ហើយ!!គេដាក់សាលា
កាលគេដាក់សាលារៀននៅ សាលារៀនខេត្តកោះកុងហ្នឹងមិនដឹងគេដាក់ស្អីញ៉ុមអត់បានចាំ!!

ក៖ចាំ!!

ខ៖ ចាំ!!

ក៖ ហ្នឹងហើយតែដឹងតែនៅខេត្តកោះកុងហ្នឹង!!

ខ៖ ចាំ!!

ក៖ ២សាលានៅបឹងត្របែកមួយនៅកោះកុងមួយដោយសារផ្លាស់ប្តូរទីលំនៅ។

ខ៖ចាំ!!

ក៖ លោកយាយពេលរៀនហ្នឹង
មុខវិជ្ជាដែលគេរៀននៅក្នុងសម័យដែលជំនាន់ពីដើមមកគេមានគណិត គីមី
អីដូចឥឡូវហ្នឹងអត់?

ខ៖ គ្មានទេកូន។

ក៖ គេរៀនពីអីគេវិញ យាយចាំទេពេលហ្នឹង?

ខ៖ រៀនពីអញ្ចេកដូចថាអក្សរអីអញ្ចឹងទៅ ហើយពីដើមយើងរៀនពីអក្សរខ្មែរ
ហើយដល់ពេលយើងចេះរៀនអក្សរខ្មែរយើងបានថ្នាក់ទី៣ ទី៤អីអញ្ចឹងទៅបានគេបង្រៀនស្អី
បានគេបង្រៀនបារាំងខ្លះ។

ក៖ហ្ហ៎!!

ខ៖ ពីដើមអត់មានអង់គ្លេសទេមានតែបារាំង!!

ក៖ ចាំគេមានលែងឡាំចូលអញ្ចឹងទៅលោកយាយ!!

ខ៖ចាំ!

ក៖ លោកយាយពេលក្តីស្រម៉ៃពីក្មេងហានៅពេលដែលកំពុងរៀនហ្នឹងហាំ
លោកយាយធំឡើងលោកយាយគិតថាចង់ធ្វើអីគេវិញ?

ខ៖ ហ៊ីនឹកឃើញថា ហ៊ីមិនចង់ធ្វើអីគេទេនេះ គ្រាន់តែចង់ធ្វើការ
ដល់ពេលនេះក៏គេហៅចូលធ្វើពេទ្យហ្នឹងក៏ញ៉ុមឈប់រៀនទៅក៏ធ្វើទៅ!!បើបានដូចថាមិនទាន់
គ្រប់អាយុផងដូចថាគេអោយយក
គេអោយយក១៧ឯខ្ញុំទឹមតែ១៦ទៅធ្វើបញ្ជីជាតិថ្មីចូលធ្វើការនៅពេទ្យហ្នឹងម៉ង។

ក៖ ហ្ហ៎ពេលហ្នឹងអញ្ចឹងទៀត!!

ខ៖ចាំ!!

ក៖អញ្ចឹងធ្វើការនៅពេទ្យជាកម្មករ!!

ខ៖ ចាំកម្មករបោកអ៊ុតហ្នឹង!!

កះនៅក្នុពេទ្យហ្នឹង!!

ខះ នៅក្នុងពេទ្យហ្នឹង។

កះអញ្ចឹងលោកយាយឈប់ធ្វើពីហ្នឹងមកដោយសារមានសង្គ្រាមហ្នឹងមែនលោកយាយ?

ខះ ញ៉ុមអត់ទាន់ឈប់ផងប៉ុន្តែដល់ពេលសង្គ្រាមយើងអញ្ចឹងទៅក៏ខានធ្វើអញ្ចឹងទៅ!!

កះ គេបិតគ្រឹបៗអស់រលីងម៉ង?

ខះ
ចាំ!!ចង់និយាយថាទៅធ្វើពីរបីល្ងាចអញ្ចឹងព្រលឹមឡើងអាពតយើងចូលដល់នេះហ្នឹងផ្លោងចូលតាខ្មៅយើងហ្នឹង មួយសំបក់ហ្នឹង!!

កះចាំ!!តាខ្មៅ។

ខះ ផ្លោងតាខ្មៅហ្នឹង ផ្សារតាខ្មៅអី អាខាងលិចផ្សារហ្នឹង
កន្លែងអាដាក់អីវ៉ាន់លក់ខាងលិចផ្សារហ្នឹង!!ពីដើមសុទ្ធតែក្រហូងប៉ុនៗណាណីហ្នំគ្រាប់ផ្លោងវាផ្លោងរាវរកអាដេញយើងបន្ទាយស៊ុប បន្ទាយទាហានស៊ុប។!

កះហ៊ឺៗ!!

ខះ ពីដើមអាយើងស្អីពោងល្ខោននៅតាខ្មៅនេះ។

កះចាំ!!

ខះអាហ្នឹងពីដើមបន្ទាយស៊ុបគេតើ!!

កះ បន្ទាយស៊ុបហ្នឹងម៉េចទៅលោកយាយ?

ខះ បន្ទាយទាហានហ្នឹងហា!!

កះ ហ្នំហ្នឹងហើយ!!កន្លែងគ្រឹះវាហ្នឹងហោ?

ខះ ហ្នឹងហើយកន្លែងគ្រឹះវា!!

កៈ កន្លែងបន្ទាយជុំនុំគេ!!

ខៈ បន្ទាយវាធំណាស់!!នៅកន្លែងហ្នឹងពីដើមកន្លែងហ្នឹងបន្ទាយទេ!!

កៈចាំ!!អញ្ចឹងលោកយាយសំរាប់បកមកការសិក្សានេះវិញ
អត់ដែលគិតថាចង់ធ្វើពេទ្យគ្រូបង្រៀនអីទេហោ?អត់ដែលគិតដល់ម៉ងហី?

ខៈ អត់ដែលនឹកឃើញចង់ធ្វើអីធ្វើអីទេ
ឮថានៅហ្នឹងអត់មាននឹកឃើញចង់ធ្វើអីផងដល់ពេលគេហៅអោយធ្វើការនៅហ្នឹងក៏ធ្វើទៅ!

កៈចាំចុះឪអីវ៉ាន់អត់មានចាអត់មានគូសវាសអោយកូន
អូមីអូនកូនធំឡើងប៉ាចង់អោយកូនធ្វើអញ្ចេះ!!

កៈ គាត់ក៏មិនចាប់អារម្មណ៍រឿងអញ្ចឹងៗដែរ!!ចាស់ៗហ្នឹង
គាត់អត់មានចាប់អារម្មណ៍ថាបង្រៀនកូនអញ្ចេះអញ្ចុះអោយធំឡើងធ្វើនេះធ្វើនោះអីអត់ទេ!!

កៈចាំ!!លោកយាយហេតុអីបានឈប់សិក្សាត្រឹមថ្នាក់ទី៧វិញ?

ខៈ នឹកឃើញថាចង់ធ្វើការហ្នឹង វាអោយធ្វើការទៅ ការហ្នឹងខ្វះអត់គ្រប់អាយុផងពេលហ្នឹង!!

កៈ ហ្ហូអីចឹងដោយសារបានធ្វើការហ្នឹងបានឈប់រៀនហ្នឹង?

ខៈ ចាំបានឈប់រៀនហ្នឹងទៅ!!

កៈ ដោយសារត្រូវការលុយដើម្បីជួយឪពុកម្តាយដែរ!!

ខៈចាំ!!

កៈហ្នឹងហើយ!!លោកយាយពេលនៅរៀនអីហ្នឹងមានមមិត្តភក្តិអីស្និតស្នាលអីអត់?

ខៈ មានអីចឹងដែរ
ប៉ុន្តែដូចថាគេមានត្រឹមតែខ្មែរក្រហាមមានត្រឹមអាពតអាអីចូលក៏បែកគ្នាអស់ទៅ!!

កៈហ៊ីៗ!

ខៈចាំ!!

កៈ គាត់ឈ្មោះអីគេខ្លះទៅ លោកយាយចាំឈ្មោះមិត្តភក្តិឈ្មោះអីគេខ្លះអត់?

ខៈ
មានដូចមីមួយនោះប្រពន្ធកម្ម៉ង់ដង់ញ៉ុមហ្នឹង‼គាត់កាលហ្នឹងសក្តិ៥‼ហ្នឹងរៀនជាមួយគ្នាដែរ‼ប៉ុន្តែវាម្តាយថៃឪពុកខ្មែរ‼

កៈហ៊ុំៗ‼

ខៈ ហើយឃើញវាកូនកាត់ហើយឃើញវាស្អាតហ្នឹង‼បានកម្ម៉ង់ប៉ុលីសហ្នឹងគេចូលស្តីទៅ‼ ហើយជួបគ្នានៅតែហៅឈ្មោះគ្នាធម្មតាហ្នឹងទៅ។

កៈចាំ‼

ខៈតែនៅមុខប្តីគេអត់ហ៊ានហៅទេ‼

កៈ ចាំ‼ឈ្មោះអីគេមិញ?

ខៈ ឈុន លឿន‼

កៈ ឈុន លឿន‼

ខៈចាំ‼

កៈ ពួកម៉ាកជិតស្និតហើយហ្នឹងហោ?

ខៈ ចាំ‼ហើយមួយទៀតឈ្មោះស្អីទេ‼ ឈ្មោះហ៊ីងហី‼ញ៉ុមភ្លេចត្រកូលវាបាត់ហើយ‼

កៈចាំ‼

ខៈ ហើយគេហៅឈ្មោះកាហ៊ីងកាហ៊ីងហ្នឹងញ៉ុម‼

កៈចាំ!

ខៈហ្នឹងប្តីធ្វើប៉ូលីសជាមួយប្តីញ៉ុមដែរ‼

កៈអ៊ីចឹងលោកយាយអត់បានរាប់អានគ្នាដល់ឥឡូវណាហី?

ខ៖អត់ទេបែកគ្នាអស់រលីងហើយ!!

ក៖មុនជំនាន់សង្គ្រាមឬក៏បែកសង្គ្រាមហើយហើយ?

ខ៖ បែកសង្គ្រាមហើយបែកគ្នាម៉ង!!កាលពីមុនសង្គ្រាមហ្នឹងនៅជាមួយគ្នារហូតហ្នឹង!!

ក៖ តែពួកគាត់បានរួចផុតពីសង្គ្រាមដែរតើយាយហោ?

ខ៖ ហ៊ីបែបរួចខ្លះអត់រួចខ្លះហើយមើលទៅហ្ន៎មើលទៅ!!

ក៖ ហ្ន៎អញ្ចឹងបាត់ពីសង្គ្រាមហ្នឹងម៉ង?

ខ៖
ចាំបាត់អត់ដែលបានជួបសោះ!!ដូចមួយចំហៀសទៅលិចមួយចំលៀសទៅកើតដើរតាមស្រុក
តាមភូមិអញ្ចឹងទៅទៅណា!!គេទៅស្រុកគេយើងទៅស្រុកយើងទៅអញ្ចឹងទៅ!!

ក៖ ចាំឥឡូវកុំអាន់អាលសួរពីប្រវត្តិប៉ុល ពត ប៉ុន្តែសួរពីរអារម្មណ៍សិន
ពេលអារម្មណ៍ពេលជំនាន់ប៉ុល ពតហ្នឹងម៉េចដែរ?ដូចរបៀបថាបាត់បង់
ជួបតែរឿងពិបាកហើយបាត់បង់មិត្តភក្តិអីវ៉ាន់!!

ខ៖ បន់ព្រះអីអស់ហើយ
ថាបើអស់លោកណាពូកែហើយមកជួយយើងជួយអីអញ្ចឹងទៅបន់អោយតែអ្នកគេមកជួយបាន
ទៅដឹងគុណគេអញ្ចឹងទៅហើយបើថាដូចថាអ្នកមានអារម្មណ៍ថាចង់រស់ទេ
ដល់ពេលពិបាកពេក បាយក៏មិនឆ្អែតអីក៏មិនឆ្អែត ហើយឃើញអាថ្ងៃគេអាពត
អាថ្ងៃគេរំដោះបានអាថ្ងៃគេកប៉ាល់ហោះ ហោះក្រឡឹងហោះអីហ្នឹង!!ពួកវាខ្លាចណាស់!!

ក៖ ពួកអាប៉ុលពតហ្នឹងហោ?

ខ៖ ហ្នឹងហើយពួកវាខ្លាចណាស់
ពួកវាឃើញអញ្ចឹងវាហៅយើងអោយចូលក្រាបអោយដូចជ្រកក្រោមដើមឈើទៅ
ហើយពួកញ៉ុមខ្លះទៅជ្រកខ្លះអត់ជ្រកទៅ!!នឹកឃើញថាងាប់ក៏ងាប់ទៅនៅឈរស្ទួងអីអញ្ចឹង
ទៅ

ញ៉ុមថ្ងៃណាវាអត់មានខោអាវដេរគេហៅទៅស្លូងអញ្ចឹងទៅ!!រាល់ថ្ងៃហ្នឹងទៅស្លូងទៅអីហ្នឹងគេទៅ!!

កៈតែកប៉ាល់ !ដូចកប៉ាល់ហោះពេញមេឃម៉ងហេ?

ខៈ ហ្នឹងហើយហោះពេញ ក្រវែលឃើញពួកយើងស្លូងឃើញអីហ្នឹងហោះអឺចឹងទៅខ្លះបក់ដៃហៅអញ្ចឹងទៅ ហើយពួកវាវាខឹងណាស់ វាខឹងយើងដូចថាឃើញអញ្ចឹងអរអែកអីអបអរសាទរអញ្ចឹងហាំ!!!ពួកវាខឹងណាស់!!

កៈ កុំអាន់អាលចូលដល់សង្រ្គាមឥឡូវបកមកតិចទៀតសិនរៀបការវីញ ការប្ដីឈ្មោះអីគេវិញ?

ខៈ ប្ដីគាត់ឈ្មោះអ៊ុំគួរ គាត់ធ្វើប៉ូលីស។

កៈ ឥឡូវគាត់អនិច្ចាកម្មឬក៏គាត់នៅរស់?

ខៈ គាត់នៅបួស។

កៈហ្ហ៎!!គាត់នៅបួសដល់ឥឡូវហ្នឹងហេ?

ខៈ ចាំ!!

កៈ នៅវត្តណាវិញលោកយាយ?

ខៈ នៅខាងវត្តស្រីសន្ធរនៅខាងខេត្តកំពង់ចាម!!

កៈចំនៅឆ្ងាយនៅណោះវិញ?

ខៈចាំ!!ស្រុកកំនើតគាត់នៅណោះគាត់ទៅហ្នឹង!!

កៈ លោកយាយម៉េចបានគាត់បែកពីលោកយាយទៅបួសហ្នឹងប៉ុន្មានឆ្នាំហើយ?

ខៈ គាត់ណែទៅ២០ឆ្នាំហើយ!!

កៈហោយូរណាស់ហើយហ្នឹង!!

ខៈ តាំងពីមីចៅនេះហ្នឹងភ្ជាប់ពាក្យហ្នឹងវានៅក្នុងពោះហ្ហ៎!!

កៈ ហ្ន៎ ហើយដល់ពេលលោកយាយដល់ពេលប្ដីគាត់អើរសំរេចចិត្តថាទៅបួសហ្នឹងម៉េចទៅ?

ខៈ សុំទៅបួស ពីដើមគាត់នៅធ្វើការនៅគមនាគមន៍ហ្ន៎!!

កៈចាំ!!

ខៈគមនាគមន៍ខេត្តកណ្ដាលយើងហ្នឹង ដល់ពេលគាត់ថាគាត់រ៉ឺត្រែតគាត់សុំទៅបួសហើយ!!

កៈហ៊ឺៗ!!

ខៈ ហើយញ៉ុមណោះនឹកឃើញគេសុំច្រើនពេក
នឹកឃើញពីក្មេងមកចេះដូចថាស្រលាញ់យើងចេះចង់បានយើងមកនៅជាមួយគ្នាដល់ពេលចាស់រៀងខ្លួនទៅចង់ទៅរកទៅបួសចង់ចោលទៅ ខ្ជិលកាលហ្នឹង
ការស៊ីញ៉េកាលហ្នឹងនៅយ៉ាវឡេងនៅឡើយ។

កៈចាំ!!

ខៈដើរទៅស៊ីញ៉េយកទៅអោយតាំងពីថ្ងៃត្រង់ហ្នឹងយកទៅអោយ
អោយកាលហ្នឹងគាត់យាមឃ្លាំង!!

កៈហាំអ៊ីចឹងទៅបួសហ្នឹងសុំលែងលះគ្នាសិនហេ?

ខៈ អត់លែងហេ!!

កៈ អត់ទេហេ?

ខៈ ចាំគាត់យាមឃ្លាំង។ហើយដល់ពេលល្ងាចឡើង
អាហ្នឹងហិ(កូនប្រុសរបស់គាត់)យកបាយទៅអោយគាត់ហូប កាលវានៅទូចហ្ន៎!!

កៈចាំ!!

ខៈ
អោយយកបាយអោយគាត់ហូបនៅកន្លែងធ្វើការហ្នឹង!!ញ៉ុមអោយយកអាក្រដាសហ្នឹងទៅអោយទៅ!!ក្រដាសគាត់ទៅនេះហ្នឹងទៅ!!

កះ ទៅណាវិញយាយ?

ខះ ទៅបួសហ្នឹង ទៅស៊ីញ៉ែអោយទៅបួសទៅ ខ្ជិល!!

កះសុទ្ធតែស៊ីញ៉ែអោយទៅបួសទៀត?

ខះ ហើយបើយើង!!

កះ ហើយគាត់ចេះតែដាច់ចិត្តទៅចោលទៀត?

ខះ
បើយើងអត់ស៊ីញ៉ែអោយគេអត់ទទួលទេ!!ព្រោះគេថាយើងរត់ចោលប្រពន្ធកូនទៅបួសអីអ៊ិចឹង ណាស់!!គេអត់ទទួលទេ!!

កះហ្ហ៎!!

ខះទាល់តែយើងហ្នឹងស៊ីញ៉ែអោយទៅ។

កះ អ៊ីចឹងក៏លោកយាយក៏តាមគាត់អញ្ចឹងទៅ??

ខះចាំ!!

កះតែដែលទៅលេងទៅអីទេយាយ?

ខះ អត់ទៅទេ ទឹមតែទៅមួយសំបក់ចូលឆ្នាំហ្នឹង
ហ្នឹងហើយចូលឆ្នាំហ្នឹងចូលឆ្នាំទៅលេងម្តងថៅវាអត់ដែលស្គាល់មុខ។

កះហ្ហ៎!!

ខះ ថៅអត់ដែលស្គាល់មុខ។

កះហើយគាត់ក៏មិនដែលមកលេងប្រពន្ធកូនដែរ?

ខះ អត់ដែលទេ!!កាលគាត់ទៅបួសហ្នឹង អ្នកណាប្រគេនលុយកាក់ហ្នឹងមិនដែលឃើញគាត់ បើគាត់យកមិនមែនប្រពន្ធកូននៅរហែមរហាមអ៊ីចឹងទេ!!

កះហ៊ឺៗ!!

ខះ យើងមើលគេបួសពីដើមនៅវត្តណាក៏ដោយនៅវត្តយើងនៅវត្តព្រៃកហូរយើងឃើញទេ ប្រពន្ធកូនអីវ៉ាន់មានក្ររហាមអី សុទ្ធតែមានម៉ូតូមានកង់អីជិះហាំ!!

កះ ហ្នឹងហើយ។

ខះ ហើយគាត់ណោះអត់ទេ!!

កះ តែគាត់បួសហើយគាត់ចេះមើលចេះអីទេលោកយាយ?

ខះ អត់ទេ គេអោយធ្វើសង្គ្រាជគាត់អត់ធ្វើផង
សុខចិត្តដើរកសាងធ្វើផ្លូវធ្វើនេះធ្វើនោះអីអឺចឹងទៅ!!

កះចាំ!!

ខះ គាត់មិនដែលនេះទេ!!

កះ
ចាំ!!លោកយាយពេលនេះមកហាំដូចជារបៀបថារៀបការជាមួយលោកតាហាំត្រូវស្រលាញ់គ្នាដោយចិត្តឯងឬក៏មានឪពុកម្ដាយរៀបចំផ្សំផ្គុំអោយពេលហ្នឹង?

ខះ
ហ្នឹងហើយគាត់ដូចថាគាត់ធ្វើប៉ូលីសហើយដូចថាម៉ែញ៉ុមគាត់ឧស្សាហ៍យកបាយសំលយកអោយមេប៉ូលីសហ្នឹងហូបទៅ ដល់ពេលដែលគេចង់បានអញ្ចឹង ម៉ែញ៉ុមក៏គាត់សួរ
ហ៊ឺកូនអើយមានឈ្មោះនេះឈ្មោះនេះគេចង់បាន
តែគេនៅកំលោះនៅអីអញ្ចឹងណាស់!!ហើយដល់អញ្ចឹងគាត់មើលគាត់អីមនុស្សហ្នឹងគាត់នៅកំលោះទេ ហើយដល់អញ្ចឹងទៅគាត់ក៏រៀបអញ្ចឹងទៅហ្នឹងទៅ
ក៏គាត់ជួយដៃរកម្ទង់ដង់ហ្នឹងគាត់ថា
គាត់ស្រលាញ់ញ៉ុមដូចម្ដាយគាត់អញ្ចឹងទៅណាស់ហើយថាគាត់ដូចប្អូនគាត់អីអញ្ចឹងទៅគាំតក៏ជួយរៀបចំអីទៅដូចកូនចៅគាត់ដែរ!!យើងពីដើមដូចថានៅចង្កាត់មាត់ញកអឺចឹងដូចវាមិនសូវមានស្អីទេ ដូចហោងហាងអីអឺចឹងទៅធ្វើអីរៀបចំការអីអញ្ចឹងទៅក៏!!

កៈ អញ្ចឹងលោកយាយតាមម្ដាយទេ!!

ខៈចាំចាំ!!

កៈ តាមម្ដាយយកប្ដីអញ្ចឹងទៅ!!

ខៈចាំ!

កៈលោកយាយដូចរបៀបថាពេលការហ្នឹងគេមានអោយជំនូនអោយអីទេយាយ?

ខៈ
ហើយយើងពីដើមហ្នឹងគ្រាន់តែយើងចូលស្ទូរល្មមៗហ្នឹងដូចថាមួយគូរពីរគូរអីអញ្ចឹងទៅមាមផ្លែឈើអីខ្លះអញ្ចឹងទៅមានតែមនុស្ស២
៣នាក់អីអញ្ចឹងទៅណាស់!!នៅចង្កាត់មាត់ញកមិនមែនដូចយើងនេះឯណា!!គ្រាន់តែថាវាគ្រាន់បើជាងពីអាពតគេរៀបទាំងគូរៗ តែដល់ពេលយើងការមានភ្លេងខ្មែរមានភ្លេងអីទៅដែរ!!

កៈហ្អ៎!!

ខៈភ្លេងខ្មែរយើងតាំងពីដើមមកយើងអត់ចោលទេ!!

កៈ ពេលការហ្នឹងការនៅឆ្នាំណាវិញលោកយាយ?

ខៈ
មិនដឹងឆ្នាំប៉ុន្មានទេកូនអើយភ្លេចបាត់ទៅហើយនេះ!!ការហ្នឹងគិតទៅការកូនញ៉ុមអាមួយបងហ្នឹងជំណាលអារិទ្ធនេះ!!

កៈចាំ!!

ខៈ ហេបង !!អាស្លាប់ទៅនេះនេះបានជំណាលអារិទ្ធនេះ!!

កៈចាំ!!

ខៈ អាយុវាចង់៥០ជាងអីហើយ!!ចូល៥០អានោះវាកើត វាចង់ចូល៥០ជាងហើយ ចូល៥២
៥៣ឆ្នាំហើយ!!

កះចាំ!!អញ្ចឹងលោកយាយអាយុប៉ុន្មានបានរៀបការ?

ខះញុំមការតាំងពី១៧។

កះអញ្ចឹងចូលធ្វើការនៅក្នុងពេទ្យ!!

ខះ ធ្វើការនៅក្នុងពេទ្យបាន១ឆ្នាំហ្នឹង!!

កះ រៀបតែម្តងទៀត?

ខះចាំ!!

កះហើយដល់ពេលដល់ពេលចេះតែរៀបការអោយតែម្តងទៅចេះតែស្រលាញ់ប្តីតាម៉ែតាមអីអញ្ចឹងទៅ?

ខះចាំ!!

កះលោកយាយពេលមានកូនពេលរៀបការហើយមានកូនប៉ុន្មាននាក់វិញ?ទាំងស្លាប់ទាំងរស់សរុបទាំងអស់ហាំ??

ខះ ទាំងស្លាប់ទាំងរស់៨នាក់។

កះចាំ!!លោកយាយចាំឈ្មោះកូនទាំងអស់តើតាំងពីបងគេរហូតដល់ពៅគេគាត់ឈ្មោះអីគេខ្លះវិញ?

ខះ បងបង្អស់ឈ្មោះស្អី!!ហោយូរទៅចង់ភ្លេចកូនអស់ហើយ!!ងាប់អស់ទៅងាប់ខ្លះទៅ!!អ៊ុំណារិទ្ធ អ៊ុំ ណារត្ន័ អ៊ុំ ណារុន ហើយបានមកមីស្រីនេះគេដាក់ឪពុកវិញ គូ ចាន់ឡុង ។

កះចាំ!!

ខះហើយបានមកអ៊ុំ ពុតធារី មកអ៊ុំ សៅឌី អ៊ុំ សៅដែន ចាំ!!

កះ ៨នាក់ហើយយាយហោ?

ខះ ចាំ៨នាក់ហើយ។

កៈ អត់មានភ្លេចអ្នកណាគេទេហី?

ខៈចាំ!!

កៈ ចុះលោកយាយកូនពៅអាយុបានប៉ុន្មានវិញបានតាទៅបួសបានតាគូទៅបួស?

ខៈ នៅប្រហែលជានៅអាយុ៧ ៨ឆ្នាំ!!

កៈអូយកូនទូចៗសោះអោយបន្ទុកលើយាយម្នាក់ឯង!!

ខៈ
អញ្ចឹងបានញ៉ុមរាល់ថ្ងៃញ៉ុមចេះតែនឹកឃើញខឹងគាត់តែពេលណាអាអស់ហ្នឹងវាកូរវាធ្វើបាបពេកនឹកឃើញថាតែឪពុកនៅក៏កូនវាមិនសូវជាហ៊ានជាមួយយើងប៉ុន្មានដែរ!!

កៈអូយ!!ញ៉ុមឆ្ងល់បានគាត់ម៉េចទៅជាអញ្ចឹងវិញម៉េចគាត់យកតែរូចខ្លួនម្នាក់ឯង!!

ខៈ ញ៉ុមថាទៅមិនរូចទេ!!កុំថាយកស្រណុកតែម្នាក់ឯងញ៉ុមថាទៅមិនរូចទេ!!

កៈហើយចុះម៉ែឪអីវ៉ាន់ខាងគាត់ខាងអីអញ្ចឹងទៅថាម៉េចទៅដល់ពេលគាត់ទៅបួសអីចឹង?

ខៈ ម្ដាយឪពុកស្លាប់តាំងមុនមានខ្មែរក្រហមហ្នឹងទៀតហ្ន៎!!

កៈហ្ន៎!!

ខៈ ហ្នឹងហើយ ម្ដាយក្មេកញ៉ុមអីស្លាប់តាំងមុនខ្មែរក្រហមអីទៀតហ្ន៎!!

កៈចាំ!!

ខៈម៉ែញ៉ុមស្លាប់តាំងពីយើងទៅអាពតហ្នឹងទៅ!!

កៈ តាយ៉ាប់ណាស់!!

ខៈចាំ!!

កៈយកតែរូចខ្លួនម្នាក់ឯងអោយយាយចិញ្ចឹមកូនតែម្នាក់ឯង។

ខៈអញ្ចឹងបានថាថ្ងៃណាខ្លះវិញញ៉ុមនឹកខឹងណាស់ បើឪពុកនៅកូនក៏មិនដល់ថ្នាក់ប៉ុណ្ណឹងដែរ!!

កៈ ចាំម៉េចដែរអ៊ំកូនខូចៗច្រើននាក់មែន?លោកយាយ។

ខៈ វាមិនខូចអីទេខូចរឿងវាផឹកហ្នឹងអូន ម៉ាវាអត់ចេះជក់ទេ!!

កៈចាំ!!

ខៈ អារឿងជក់ម៉ាវាស្អប់ណាស់ប៉ុន្តែបើផឹក!!

កៈផឹកមុជម៉ងហោ?

ខៈ តែតិចទៀតហ្នឹងទារលុយយើងទិញស្រាផឹកទៀតឥឡូវហើយ ការងារមានមួយថ្ងៃ៦០០០០អត់ព្រមទៅធ្វើទេ!!វាមកតាំងពីខូបកំនើតក្មួយហ្នឹងមកហាតាំងពីភ្ជាប់ពាក្យក្មួយហ្នឹងមកអត់ទាន់ទៅវិញទេ!!

កៈ ចាំហ្នឹងហើយ ហើយមាននប្រពន្ធមានកូននៅ?

ខៈ នៅ !!មានអាណាគេយកទេប្រមឹកអែប្រម៉ែអញ្ចឹង!!

កៈ ហើយកូនរៀបការហើយអស់នៅ?

ខៈ រៀបអស់ហើយ។

កៈតែនៅតែមួយហ្នឹងទេហី?

ខៈ ប៉ុន្តែស្លាប់ ស្លាប់អស់ប៉ុន្មាននៅសល់តែ៥នាក់ទេ!!ស្លាប់អសស់៣ហើយ!!កាលនៅជំនាន់អាពតហ្នឹង!!

កៈ ហ្អ៎អ៊ីចឹងកូនស្លាប់អស់៣នាក់ហើយ?

ខៈ ជំនាន់អាពតរលាកពេញខ្លួនហ្នឹងងាប់អស់ពីរ!!

កៈ ឥឡូវលោកយាយនិយាយមើលមូលហេតុអីគេបានរលាកភ្លើងរលាកអីអញ្ចឹង?ស្នាមទល់ឥឡូវ!!

ខ៖ អាហ្នឹងមកអំពីជំនាន់ ពេលហ្នឹងអត់ទាន់អាពតទេ
ពេលហ្នឹងវានៅខ្មែរក្រហមនៅឡើយទេ!!ក៖ចាំ!!ខ៖ហ្នឹងហើយដល់ពេលវានៅនឹងជើងភ្នំអញ្ចឹង
ទៅ!!វាបាញ់គ្រាប់ផ្លោងចូលមកហើយខ្ញុំណោះធ្វើត្រង់សេនៅខាងមុខផ្ទះអញ្ចេះហ្ហ៎!ហើយចងមុ
ងក្រាល ហើយត្រង់សេយើងមិនដាក់ដី ដាក់ដីយើងមិនដាក់កៅស៊ូក្រាលពីលើ
ដល់ពេលវាបាញ់មកវាសើយអាដីហ្នឹងទៅអស់ទៅវាឆេះអាកៅស៊ូឆេះទាំងមុងនៅក្នុងហ្នឹង
យើងយកអត់ទាន់ យកកូនអត់ទាន់
យើងយកចេញមកពេលយើងតេហៅកប៉ាល់ហោះអោយទៅយកនៅផ្លូវជាតិលេខ៥ហ្នឹង
វាយើងនៅជិតស្រែអំបិលហ្នឹងពេលអោយអាកន្ទុំរុយទៅយកហ្នឹងវាបាញ់ផ្លោងមកអញ្ចឹងហ្នឹង!!
!កប៉ាល់ហោះហោះឡើងអញ្ចឹងមើលតែស្ងាត់បានចុះទៅយកយើងម្តងទៀត
បានយកមកនៅពេទ្យធំហ្នឹងពួកកូន២នាក់ហ្នឹងមកងាប់នៅពេទ្យធំទាំងអស់!!

ក៖ ហ៎ា!!អញ្ចឹងពេលឆេះហ្នឹងដោយសារការធ្លាក់គ្រាប់ទេអញ្ចឹងហេ?

ខ៖ចាំ!!

ក៖ សាចមក?

ខ៖ ហ្នឹងហើយ យើងបាញ់ទៅវាសើយអាជំបូលហ្នឹងវាឆេះ ឆេះមុងឆេះអីទាំងអស់។

ក៖ ពេលហ្នឹងយាយត្រូវរបួសហើយកូនស្លាប់២នាក់ទៀត?

ខ៖ចាំ!!

ក៖ អើយអារម្មណ៍ពេលហ្នឹងម៉េចទៅយាយអើយងាប់បណ្តោយ!!ម៉េចដែរយាយពេលហ្នឹង?

ខ៖ អត់ទេគេដាក់កូនផ្សេងៗពីគ្នាមិនដឹងគេមិនដឹងអោយកូនស្លាប់ផងហ្នឹង!!

ក៖ហ្ហ៎ដោយសារពេលហ្នឹងលោកយាយត្រូវរបួសខ្លាំងហេ?

ខ៖ ហ្នឹងហើយយើងអត់ដឹងផង
ដល់ពេលយើងជាហើយបានយើងរកសួររកកូនទៅបានគេប្រាប់។

ក៖ ថាស្លាប់អ៊ិចឹងម៉ងទៅ?

ខ៖ ម៉ែញ៉ុមគាត់ប្រាប់គាត់ចង់ហ៊ានប្រាប់ផងហ្នឹង
យើងចេញមកផ្ទះអស់ហើយហ្នឹង!!គាត់ចេះតែកុហកថាកូននៅផ្ទះ
ដល់ពេលយើងមកដល់ផ្ទះយើងអត់ឃើញកូនបានគេបងប្អូនអីគេប្រាប់នឹកឃើញថាអើរបើវា
ទៅទៅហើយ បើវាយូរទៅហើយគេទឹមតែប្រាប់អញ្ចឹងក៏វារាងណាយចិត្តទៅ
វាអត់ឃើញនៅហ្នឹងភ្នែកហា៎!!

ក៖ ចា៎!!ពេលហ្នឹងប៉ុន្មានខែហើយយាយបានទឹមតែប្រាប់ហ្នឹងយាយ?

ខ៖ ហ៊ីកាលហ្នឹងញ៉ុមដេកពេទ្យកាលហ្នឹងដេកយូរដែរហ្នឹង!!ទាល់
អត់ទាន់ជាស្រួលប្រួលផងនៅស្នាមនៅអី ញ៉ុមចេញមកហ្នឹងនៅស្នាមក្រមែក្រម៉ហ្នឹង
ញ៉ុមចេះតែកេសទៅ អត់ទាន់ជាស្រួលប្រួលផងហ្នឹងវេទនាផ្តាច់ស្តានជ្រោយចង្វានោះ!!

ក៖ហ្ហ!!

ខ៖ កាលសំបក់ហ្នឹងឡើងរំជួយផ្ទះយើងពេទ្យធំហ្នឹង យើងពេទ្យធំដែរនោះ
ហើយញ៉ុមខ្លាចស្អែកឡើងសុំលោកដុកទ័រចេញមក។

ក៖
ចា៎អញ្ចឹងរៀងយូរដែរហ្នឹងអិចឹងទំរាំដឹងហើយលោកយាយពេលហ្នឹងគ្រាន់តែរបួសត្រូវពេញខ្លួន
ឬក៏ម៉េចដែរ?

ខ៖ វាសើយមកយើងទៅយកកូនទៅយកអាចេញយើងចេញមក
វាឆេះមុងយើងចេញមកវាអត់មានត្រូវរបួសអីទេ តែអាចំហាយយើង អាចំហាយវាក្តៅហ្ហ៎!!

ក៖ហ្ហ៎!!

ខ៖ ចំហាយក្តៅវាស្នាមពេញមុខពេញអីទាំងអស់សក់អីឡើងរួញទាំងអស់។

ក៖ហ្ហ៎អញ្ចឹងអាចំហាយក្តៅមកវាជប់មកវាក្តៅអញ្ចឹងម៉ងហោ?

ខ៖
ហ្នឹងហើយដល់ពេលយើងជិះអាកប៉ាល់ហោះហ្នឹងមកភ្នំពេញហ្នឹងហា៎ដូចវាត្រូវខ្យល់ធាតុអាកា
សទៀតឡើងហើមខ្លួនឡើងពងបែក!!

កៈ ឡើងស្លោកម៉ងហោ!!

ខៈ ឡើងពងបែកពេញខ្លួនម៉ងទៅណាស់!!

កៈ ហ្នឹងហើយអារឿងស្លោកហ្នឹងទៅពងពងមក!!

ខៈ ពេញដៃពេញជើងទាំងអស់ហ៎!!ឡើងពេញខ្លួន។

កៈតែពេលហ្នឹងយាយពេលហ្នឹងពេលអាត្រូវចំហាយហ្នឹងមកសន្លប់ឬក៏ម៉េច?

ខៈ អត់អីដែរ។

កៈអត់អត់ អត់អីដែរ?

ខៈ ចា៎!!ដូចថាស្មារតីននៅ នៅចូលទៅយកកូនយកអីយកអីមកក្រៅ។

កៈចា៎!!

ខៈឪពុកខ្ញុំអីវ៉ាន់ជួយទៅយកមកក្រៅ!!

កៈ តែទៅយកហ្នឹងកូនស្លាប់ហើយទេហោពេលហ្នឹង?

ខៈ នៅទេ មកស្លាប់នៅពេទ្យធំណោះ!!

កៈហ្ន៎អីចឹងមកដល់ពេទ្យហើយបានស្លាប់ក្រោយ!!

ខៈ ចា៎ចា៎!

កៈអានិតកូនណាស់អីចឹងយាយអើយ!!អីចឹងលោកយាយរៀបរាប់ពីជីវិតលោកយាយពេលជំនាន់សម្តេចមកថាលោកយាយជួបរឿងអីគេខ្លះពេលជំនាន់សម្តេចហា៎?

ខៈ
ពីជំនាន់សម្តេចអត់មានជួបអីគេទេព្រោះអីទៅជាមួយឪពុកទៅធ្វើការធ្វើអីនៅខេត្តកោះកុងណោះ!!ទឹមមកយើងជំនាន់លន់ នល់។

កៈចា៎ឥឡូវឈប់លោកយាយទាន់ជំនាន់អាតស្សរអីអត់ ឬអីអត់ពីតស្សរ?

ខះពេលនៅឥស្សរហ្នឹងនៅទូចៗហ្នឹងញ៉ុមនៅទូចៗទេ!!

កះ ហើយចាំអីអត់ពីមុន?

ខះ មិនជាចាំអីណាស់ណា
ប៉ុន្តែថាសំបក់ហ្នឹងឪពុកញ៉ុមគាត់រកស៊ីលក់ដូរអីគាត់លក់គុយទាវលក់អីដល់ពេលនៅពេលជំនាន់ឥស្សរហ្នឹងសម័យឥស្សរនេះគាត់នៅដូចថានៅក្រៅភូមិអីចឹងហាំ!!លក់គុយទាវលក់អីអោយអ្នកបោកស្រូវបោកអីអីអញ្ចឹងទៅ!!គាត់ធ្វើនៅក្រៅភូមិ!!ដល់ពេលហ្នឹងញ៉ុមនៅទូចម៉ែញ៉ុមគេចាប់ឪពុកញ៉ុមយកទៅទៅម៉ែញ៉ុមលើកញ៉ុមពរយកញ៉ុមមកផ្ទះបងប្អូននៅក្នុងភូមិនេះវិញហ្នឹងដឹងតែពេលជំនាន់ហ្នឹង
តែដល់ពេលហ្នឹងពេលព្រលឹមឡើងហ្នឹងឃើញឪពុកញ៉ុមគាត់រួចមកមកខ្លះគេយកទៅសម្លាប់ចោលទៅ ហើយឪពុកខ្ញុំហ្នឹងហើយនឹងឪពុកធំមួយទៀតរត់រួច
រត់រួចមកឈរដង្ហក់ដង្ហើមត្រហែបត្រហបហ្នឹង
ហើយតាំងពីហ្នឹងមកក៏ហែទៅ!!ហើយកាលហ្នឹងអត់ឃើញពួកអីឥស្សរអី ពួកបារាំងពួកអីជិះសេះដើររកពួកឥស្សរហ្នឹង!!

កះ អីចឹងឥស្សរហើយនឹងបារាំងហ្នឹងវាប្រឆាំងគ្នាម៉ងហេ?

ខះ
ហ្នឹងហើយវាអត់ត្រូវគ្នាបារាំងវាដើររកចាប់ពួកឥស្សរពួកអីហ្នឹងហើយយើងពីដើមអ្នកស្រុកពីដើមមានសុទ្ធតែឥស្សរ តែដល់ឃើញអីចឹងដល់នេះខ្លះចេះតែគេចរួចរត់ពួនរត់អីអញ្ចឹងទៅ!!!

កះតែឥស្សរហ្នឹងខូចមែនទេយាយ?

ខះ ឥស្សរហ្នឹងដូចជាមិនខូចទេដូចថាអ្នកស្រុកចាំភូមិចាំស្រុកយើងដូចរាល់ថ្ងៃអីអញ្ចឹងទៅ។

កះហ្ហ៎ប៉ុន្តែញ៉ុមឃើញអ្នកខ្លះថាឥស្សរសម្លាប់មនុស្ស!!

ខះ ឥស្សរហ្នឹងកាលមុនដូចជាសម្លាប់ដែរ សម្លាប់ដូចថាអ្នកណារឹងទទឹងអីអញ្ចឹងទៅណាស់។

កះហ្ហ៎អញ្ចឹងដូចអ្នកការពារអីអញ្ចឹងដែរទៅអីចឹងណាស់!!

ខះ អ្នកណារឹងទទឹងអីអញ្ចឹងគេសម្លាប់អីអញ្ចឹងទៅ!!

កះ ឥឡូវលោកយាយនិយាយចូលដល់ពេលជំនាន់លន់
នល់មើលលោកយាយជួបរឿងអីគេខ្លះ?

ខះ ជំនាន់ហ្នឹងញ៉ុមដូចអត់មានអីទេ
ញ៉ុមដូចធ្វើការធ្វើអីជួបតែរឿងគ្រាប់ផ្លោងគ្រាប់អីអញ្ចឹងទៅការណាបាញ់គ្នាទៅកូនអីនៅជាមួយម៉ែនៅកំពង់សំណាញ់
ដល់ពេលវាទំលាក់គ្រាប់ទំលាក់អីហ្នឹងជាទៅញ៉ុមនៅជាមួយម៉ែនៅកំពង់សំណាញ់នៅអីទាំងអស់ អីជឹងទៅទៅតែពីរនាក់ប្ដីប្រពន្ធទៅតែធ្វើការទៅ ធ្វើខ្លួនឯងផងអីផង
ដូចថាគេខ្មែរក្រហមគេបាញ់មកអីទៅចេះតែនៅក្នុងត្រង់សេ អាប្ដីបាញ់ទៅ
ចេះតែជួយច្រកគ្រាប់ច្រកអីគេអញ្ចឹងទៅ!!ច្រកដាក់បង់អីបង់គេបង់ងគេហ្នឹងហាំ!!

កះចាំ!!

ខះជួយចេះតែច្រកនឹងគេទៅ!!ច្រកតាមប្រហោងគេគេអង្គុយចេះតែអង្គុយនឹងគេទៅក៏ច្រកចេះតែជួយគេទៅ!!

កះហ្ហ៎អ៊ីចឹងប្ដីលោកយាយគឺជាទាហានលន់ នល់?

ខះ ដំបូងធ្វើប៉ូលីសទេ ដល់ពេលយើងគេទំលាក់សម្ដេចចោលទៅហ្នឹង!

កះចាំ!!

ខះគេថាប៉ូលីសវាច្រើនជាទាហានម្ល៉ោះហើយគេអោយប៉ូលីសហ្នឹងចូលជាទាហានទាំងអស់វិញ។

កះ ហ្ហ៎!!

ខះហ្នឹងហើយ។

កះ អ៊ិចឹងទៅបាញ់អីអញ្ចឹងទៅ?

ខះ ជាមួយគេជាមួយឯកអីចឹងទៅ!!

កះ ពេលបាញ់ហ្នឹងទីតាំងនៅឯណាវិញយាយ?

ខ៖ ទីតាំងនៅអនុខេត្តកំពង់សិលា។

ក៖អ៊ីចឹងនៅខេត្តកោះកុង។

ខ៖ នៅក្នុងអនុខេត្តកោះកុង។

ក៖ចាំ!!

ខ៖ អនុខេត្តកោះកុង!!

ក៖ ហ្នឹងហើយ ហ្នឹងហើយលោកយាយ ញ៉ុមទឹមតែរកនឹកឃើញ
យាយជួយដាក់គ្រាប់កាំភ្លើងអីវ៉ាន់ទៀត?

ខ៖ ហ្នឹងហើយ។

ក៖ ពេលហ្នឹងគ្រាប់ធំៗទេយាយ?

ខ៖ ហ៊ីអាគ្រាប់យើងប្រវែងៗនេះហ្នឹង!!

ក៖ ហ្នុំអ៊ីចឹងយាយចេះរៀបបង់កាំភ្លើងអីទៀត?

ខ៖ ចាំ!!

ក៖ ចុះឥឡូវនៅចាំទេ?

ខ៖ ហើយបើឥឡូវបើអោយច្រក ច្រកកើត!!

ក៖ចាំ!!លោកយាយមានគេប្រាប់អត់ គោលបំណងនៃការបាញ់ហ្នឹងបាញ់អ្នកណាគេដែរ?

ខ៖ បាញ់ដេញអាពួកខ្មែរក្រហមដេញវាបាញ់ចូលមកយើងហ្នឹង ។

ក៖ ហ្នុំអ៊ីចឹងបាញ់តទៅវិញទៅ?

ខ៖ ចាំបាញ់តទៅវិញការពារខ្លាចវាចូលបន្ទាយយើង។

ក៖ ហ្នុំអ៊ីចឹងពេលបាញ់ បាញ់មកហ្នឹងបាញ់នៅបន្ទាយទេអ៊ីចឹង?

ខ៖ បាញ់ វាបាញ់ចេញពីក្នុងព្រៃទេ យើងបាញ់ចេញពីបន្ទាយទៅវិញ។

ក៖ ហ្ន៎អ៊ីចឹងវាបំរុងនឹងកំទេចបន្ទាយហ្នឹងយាយណោះ?

ខ៖ ចា៎!!!ក៖ហ្ន៎!!ខ៖ ហើយពេលហ្នឹងដូចវាថាកាចឹបសងខាងហា!!
កំពង់ស្ពឺវាវ៉ៃដាច់ផ្លូវហួសពេជ្រនិលមក មកក្រោយបន្តិចមក !!

ក៖ហ៊ឺៗ!!

ខ៖ ហ៊ឺអាខាងយើងកំពង់សោមវាដាច់នៅហួសវាលរេញនៅត្រង់អូរត្រាវអូរអើហ្នឹង
ហើយយើងនៅប្រលោះកណ្ដាលយើងអត់មានអីហូបទេ កប៉ាល់ហោះទំលាក់អោយស៊ីទេ!!

ក៖ ហ្ន៎អ៊ីចឹងសុទ្ធតែស្បៀងទាំងអស់គឺខាង!!

ខ៖ ហ្នឹងហើយទំលាក់ខាងកប៉ាល់ហោះចា៎!!

ក៖ លន់ នល់ ផ្តល់ស្បៀងអោយមកអញ្ចេះវិញ?

ខ៖ ចា៎ចា៎!!

ក៖ មានអេកូមអីសំរាប់ទាក់ទងអីទេយាយ?

ខ៖ មាន គេអីខាងសាលាខេត្តគេមាន !!

ក៖ហ៊ឺៗ!!

ខ៖
យើងប្រជាជនយើងអត់មានទេ!!ហើយយើងកូនទាហានកូនអីយើងអត់មានទេ!!មានដូចយើង
អីដូចតាមក្រសួងតាមកន្លែងយើងធ្វើការនីមួយៗអ៊ីចឹងអីគេចូលសាលាខេត្តគេចូលអីអាហ្នឹងមា
ន!! តែយើងអត់មានដូចឥឡូវមានគ្រប់ដៃអ៊ីចឹងទេ!!

ក៖ បាញ់អាពតត្រូវខ្លះទេយាយពួកខ្មែរក្រហមហ្នឹង?

ខ៖ ហ៊ឺត្រូវខ្លះដែរមើអូន ជួនកាលកាត់ក្បាលយួរមកក្នុងបន្ទាយមានអីក៏មានដែរ។

កៈ អូយ!!ងាប់ហើយយាយ អ្នកណាគេអ្នកកាត់ក្បាលមកវិញ?

ខៈ ពួកទាហានហ្នឹង។

កៈ ចំសាហាវណាស់!! តែប្ដីយាយអត់អីទេហោ?

ខៈ គាត់អត់ទេ!!

កៈ គាត់អត់សូវហ៊ានទេហោ?

ខៈ និយាយនិយាយរួមមកតាហ្នឹងគាត់អាចារ្យតាំងពីដើមមកអត់រវល់ទេអញ្ចឹងៗ!!

កៈ ចាំតែគេអោយធ្វើទាហានហើយចេះតែតបតអីចឹងទៅ!!

ខៈ អ្នកណាអោយធ្វើអីចេះតែធ្វើទៅញ៉ុម តែគាត់ធ្វើការ ធ្វើការនៅប៉ារ៉ូលទេ!!
គាត់អត់ដែលចេញទៅណាទេ!!

កៈ ចា៎!!ហើយម៉េចបាន ដល់ពេលអើរវាខ្លាំងពេកអញ្ចឹងទៅ
បានចេញបាញ់អញ្ចឹងទៅហោពីបន្ទាយទៅ?

ខៈ ហ្នឹងហើយ
អាហ្នឹងហើយបើយើងមិនជួយការពារបន្ទាយគ្នាខ្លាចវាចូលមកវាសម្លាប់អស់ទៅ!!

កៈ ហ្នឹងហើយ!!

ខៈ ហើយបើថាវាបានចូលហើយសូម្បីតែកូនក្មេងនៅក្នុងអង្រឹងក៏វាមិនទុកដែរ។

កៈ ហ្នឹងហើយ ហ្នឹងមែនហ្នឹងពួកអាហ្នឹងវាសាហាវណាស់យាយ!!

ខៈ ហ្នឹងហើយសាហាវណាស់!!

កៈ យាយដឹងថាអាពួកខ្មែរក្រហមហ្នឹងវាបង្កើតមកពីអ្នកណាគេវិញទេ?

ខៈមិនដឹងទេកូន មិនដឹងកើតពីណាមកផង!!

កៈចា៎!!

ខ៖ ស្រាប់តែឃើញចូលមកពេញស្រុកពេញទេសពេញភូមិអញ្ចឹងទៅ!!

ក៖ ហ៊ីយ៉ាប់ណាស់ !! ហើយយាយពេលហ្នឹងមានលឺអីពីស្ដេចទៀតអត់ ដល់ពេលទំលាក់មក គេមានដែលនិយាយអីពីស្ដេចយើងទៀតទេ?

ខ៖ អត់ទេមានដែលនិយាយអីផង
ថាមួយៗយើងចាស់ៗពីដើមមួយៗចេះតែជួយអានិតសម្ដេចឪអីចឹងទៅ។

ក៖ ដោយសារស្រលាញ់ស្ដេច។

ខ៖ ហ្នឹងហើយស្រលាញ់សម្ដេចថាគាត់ពីដើមគាត់ទៅណាមកណា
លុយកាក់អីគាត់សុទ្ធតែបាចអោយកូនចៅ
ហើយក្រណាត់នៅពេលសង្គមរាស្ត្រនិយមពីដើមមកហើយគាត់បោះក្រណាត់ហៃងទាំងកីៗ
តាមកប៉ាល់ហោះតាមអី ហ្នំមួយៗនឹកឃើញស្រលាញ់អានិតសម្ដេច។

ក៖ ហ្នឹងហើយ ពេលជំនាន់គាត់គ្រប់គ្រងសប្បាយណាស់លោកយាយហេ?

ខ៖ ហ្នឹងហើយ ចាំ!!

ក៖ តែលោកយាយផ្ទត់គំនិតមួយៗពេលហ្នឹងស្អប់លន់ នល់ ខ្លាំងទេ?

ខ៖ ហ្នឹងហើយស្អប់
ឃើញទំលាក់សម្ដេចអីមួយៗនិយាយថាមិនគួរទំលាក់សម្ដេចឪអស់រលីងហើយហ្នឹង!!

ក៖ តែយើងអត់ដឹងរឿងផ្ទៃក្នុងថាមូលហេតុអីហ្នំ!!

ខ៖ ចាំមិនដឹងជាយ៉ាងម៉េច!!មិនដឹងនយោបាយរបស់គេគិតតែពីខឹងហ្នឹងកាលហ្នឹង!!

ក៖ ហ្នឹងហើយ!!

ខ៖ កាន់ជើងសម្ដេច!!

ក៖ និយាយទៅពេលខ្លះយើងអត់ដឹងរឿងទាំងអស់មែន
តែពេលខ្លះដូចរបៀបថាការសំរេចរបស់អ្នកដឹកនាំតែម្នាក់សោះធ្វើអោយរាស្ត្រមួយនគរវេទនា
ពិបាកអីចឹងណាស់យាយណាស់!!ខ៖ចាំ!!

កៈបើគេដឹកនាំស្រួលទៅយើងបានស្រួលទៅរស់ !!

ខៈចាំ!!

កៈតែបើគេដឹកនាំខុសចូលភ្លើងសង្គ្រាមអីហ្នឹងគឺថាវេទនាអស់សព្វគ្រប់ម៉ងហាំ!!ហ៊ីយ៉ាប់ណាស់យាយអើយ!!!អ៊ីចឹងលោកយាយចូលដល់ជំនាន់ប៉ុល ពតវិញ
យើងថ្ងៃដំបូងនៃជំនាន់ប៉ុលពត លោកយាយម៉េចខ្លះ
លោកយាយប្រាប់ថាធ្វើការនៅក្នុងពេទ្យធំសុខៗសោះហ្នឹងហី?

ខៈ ហ្នឹងយើងនេះហើយហើយ
យើងដល់ពេលយើងចេញពីនោះមកថាយើងងាប់កូនងាប់ចៅហ្នឹងយើងសុំគេមកធ្វើការនៅពេទ្យធំហ្នឹង!!

កៈចាំ!!

ខៈដល់ពេលខ្មែរក្រហមចូលពេញភ្នូមិអញ្ចឹងទៅគេជំលៀសយើងចេញហ្នឹង!!

កៈចាំ!!

ខៈ
ហ្នឹងជំលៀសយើងចេញហ្នឹងគេជំលៀសថ្ងៃហ្នឹងប៉ះដូចថ្ងៃស្អីទេ!!ប៉ះចំថ្ងៃអាទិត្យថ្ងៃអីមិនដឹងទេ សំរាកមូលគ្នាទាំងអស់ហ្នឹង ទៅធ្វើការក៏ទៅមិនកើតគ្រាប់ផ្លោងខ្លាំងពេកកាលហ្នឹង
បើយើងនៅផ្ទះគេចេះគេថាគេចូលដល់តាខ្មៅអ៊ីចឹង ចេញៗៗៗៗៗៗៗ
គេចេះតែអោយយើងចេញអោយអស់មានយកអីទៅទេ
ខោអាវអីវ៉ាន់ក៏មិនបានយកទៅស្លៀកពាក់អីផងហ្នឹង!!

កៈ អ៊ីចឹងលោកយាយពេលនៅក្នុងជំនាន់លន់ នល់ លោកយាយនៅឯណាវិញ?

ខៈ យើងមកនៅកំពង់សំណាញ់វិញ!!

កៈ មកវិញហើយ!!

ខៈចាំ!!

កៈ តែពេលអាពេលជំនាន់លន់ នល់ ពេលមុនពេលនោះនៅកំពង់សិលា!

ខៈ នោះនៅកំពង់សិលា!!

កៈហើយបានប្តូរមកវិញ!!

ខៈ ដល់ពេលងាប់ចៅ ដល់ពេលងាប់កូនអស់ហើយក៏ឈប់ទៅ ក៏សុំគេមកនៅ!!

កៈភ្នំពេញវិញទៅ?

ខៈ ភ្នំពេញវិញទៅ!!នៅពេទ្យធំភ្នំពេញវិញ!!

កៈ កូនពេលហ្នឹងស្លាប់ទៅអស់ម៉ងយាយហេ?

ខៈ ស្លាប់ទៅ២។

កៈ ស្លាប់២!!តែនៅសល់ប៉ុន្មានទៀតពេលជំនាន់ហ្នឹង?

ខៈ ហើយមួយទៀតទឹមតែស្លាប់ពេលអាចំបក់អ៊ុនតាក់ចូលនេះទេ!!

កៈហ្ហ៎!!ចាំ!!អ៊ីចឹងនៅសល់៥នាក់ណោះ?

ខៈ នៅសល់៥ ចាំ!!

កៈហ្នឹងហើយ អ៊ីចឹងលោកយាយនិយាយតទៀតពីជំនាន់សង្គ្រាមប៉ុល
ពតទៀតមើលអោយបានក្បោះក្បាយអ៊ីចឹងទៅណាស់!!

ខៈ មិនដឹងនិយាយអីផងមីអូន
កាលយើងទៅកាលយើងទៅអាពតហ្នឹងជូនកាលគេអោយតែបាយយើងហ្នឹងជូនកាលអាបាយ
មួយខ្ទះហ្នឹងគេដាក់អង្ករតែ៥កំប៉ុងហើយអាដេញស្អីពោតក្រហមដាក់លាយក្រហមផ្អឹសពេញ
ឆ្នាំងហ្នឹងទៅ!!

កៈ ពោតក្រហមរឹងណាស់យាយហេ?

ខៈ ពោតក្រហមរឹងរំងាស់!! ខ្ញុំម៉ាស្របក់ហ្នឹង ញ៉ុមចាញ់កូន
ចាញ់ម៉ែវាហ្នឹង(និយាយចង្អុលទៅចៅ)អត់មានហូបអីកើតទេ!!

កៈ
អ៊ីចឹងលោកយាយសំរាប់ពេលហ្នឹងដូចជាលោកយាយប្រាប់មិញថាលោកយាយគេអោយដេរហោ?

ខៈ ចាំគេអោយដេរ ។

កៈតែដូចជា!!

ខៈ
តែថ្ងៃណាខ្លះយើងអត់ដេរអត់អីអញ្ចឹងទៅបានគេអោយយើងទៅជួយស្ទូងទៅជួយអីខ្លះអញ្ចឹងទៅ!!

កៈចាំ!!

ខៈ ជួយច្រូតជួយអីខ្លះអ៊ីចឹងទៅ!!បើអត់មានអីដេរ គេអត់អោយយើងនៅស្ងៀមទេ។

កៈ ចាំ!!គឺថាមួយៗត្រូវតែសកម្មម៉ងយាយហោ?

ខៈ ចាំ!!មិនមែនថាអត់អីដេរគេអោយយើងនៅប្រចាំការនៅហ្នឹងទេ
តែអត់អីដេរគេប្រើយើងអោយទៅណេះទៅណោះអ៊ីចឹងទៅ!!គេអត់អោយនៅទេ។

កៈ តែលោកយាយគ្រាន់ធូរបានធូរដែរ !!

ខៈ ធូរខ្លះ!!

កៈ ដោយសារបានចេះដេរហ្នឹង!!

ខៈ ចាំបានធូរខ្លះៗ!!

កៈ ជាងដេរអត់សូវមានច្រើនទេយាយហោ?

ខៈ មាន២នាក់ ស្រី២នាក់ប្រុសម្នាក់។

កៈ ដល់ពេលគេអោយដេរហ្នឹងគេអោយដេរអាខោអាវខ្មៅៗហ្នឹង?

ខ៖ គេអោយដេរអាខោអាវខ្មៅៗហ្នឹង ហើយក្រមាគេអោយចែកអញ្ចឹងទៅហើយខោអាវដេរហ្នឹងមានអីមានតែខោអាវខ្មៅ ស្បែកជើងកង់ឡានហ្នឹង!!

ក៖អត់អីក្រៅពីហ្នឹងទេហេ?

ខ៖ ចាំ!!

ក៖ យាយពេលហ្នឹងគឺថាខ្មៅគ្រប់គ្នាម៉ង?

ខ៖ ហ្នឹងហើយ សុទ្ធខ្មៅ គណៈកងគេសុទ្ធតែខ្មៅ យើងស្លៀកពាក់អីស្លៀកពាក់ទៅ អាខោអាវយើងទៅពីនេះទៅខ្លះអីខ្លះហ្នឹងចេះតែស្លៀកទៅ។

ក៖ ហ្នំអញ្ចឹងស្លៀកពណ៌បានដែរហេ?

ខ៖ ចាំស្លៀកពណ៌បានខ្លះហើយខ្លះទៅគេចែកខ្មៅៗអោយទៅទៀត ស្លៀកទៀតទៅ!!ក៖ ហ៊ីៗ!!ខ៖កាត់ស្លៀកកាត់អីអញ្ចឹងទៅ!!

ក៖ហើយយាយមិញលោកយាយប្រាប់ថាពេលគេជំលៀសចេញហ្នំ អត់បានយកខោអាវយកអីទៅទេហេ?

ខ៖ អត់បានយកទៅច្រើនទេ យកបានតែខោអាវ៤ ៥ទៅ។

ក៖ គេប្រាប់ថាម៉េចយាយ?

ខ៖ គេថាអោយយើងចេញសិន ចេញមួយរយៈមានស្អី ឥវ៉ាន់នៅផ្ទះទាំងអស់អាពេលយើងបែកហើយចូលមកវិញគេរូសអស់រលីងនៅតែដីទទេ!!

ក៖ញ៉ុមឆ្ងល់ផ្ទះប្រជាជនមិនមែនតិចទេយាយហាំ!!

ខ៖ ហ៊ីរូសទាំងអស់មីអូន។

ក៖ហើយរូសហ្នឹងវាយកទៅធ្វើអីគេ?

ខ៖ មិនដឹងរូសយកទៅធ្វើស្អី យកទៅធ្វើស្អីវាអីណាណីមិនដឹងទេ!!

កៈឆ្ងូត!!

ខៈ វារូសអស់រលើងអាណាផ្ទះធំៗអញ្ចឹងជូនកាលវាដាក់កងទ័ពវាហ្នឹងបាននៅ
បើថាអត់ដាក់មានអត់មានកងវារស់នៅទេវារូសអស់ហើយ។

កៈហ៊ឺ!!យាយនៅខេត្តណាវិញពេលនៅសង្គ្រាមហ្នឹង?

ខៈ អាពេលយើងជិតបែកហ្នឹងញ៉ុមមកនៅកំពង់សំណាញ់វិញ ។

កៈ តែពេលនៅសង្គ្រាមអាពេលកំពុងតែក្តៅកគុកម៉ងហាំ??

ខៈ
កាលពេលហ្នឹងខ្ញុំកំពុងនៅក្នុងអនុខេត្តកំពង់សិលាហ្ន៎!!ម៉ែញ៉ុមនៅកំពង់សំណាញ់ណោះ!!កៈហ្ន៎
!!ខៈ នៅជាមួយកូនចៅញ៉ុមទុកនៅណោះទុកអោយគាត់នៅមើលហ្ន៎!!

កៈ គេជំលៀសយាយទៅកំពង់សិលាណោះវិញ?

ខៈ ញ៉ុមទៅនៅណោះ កាលញ៉ុមផ្លាស់ពីអនុខេត្តកោះកុងមកនៅអនុខេត្តកំពង់សិលាហ្នឹង!!

កៈ ចាំ!!ប៉ុន្តែពេលនៅក្នុងសង្គ្រាមប៉ុល ពតម៉ងហាំយាយហាំ?

ខៈ ហ្ន៎នៅប៉ុល ពតញ៉ុមចេញចេញអញ្ចឹងទៅខាងស្ពានព្រែកតូចអញ្ចឹងទៅ
ដល់ពេលនេះគេថាហ៊ីទៅខាងកន្លែងស្ពានព្រែកតូចវាអត់សូវមានអីហូបទេ
ដែលគេស្គាល់ឪពុកខ្ញុំហ្ន៎ ដល់ហើយគេថាមិត្តឯងទៅនៅឯណា!!
ពួកហ្នឹងគេហៅថាតែមិត្តមិត្តនោះ មិត្តឯងស្រុកកំនើតនៅឯណាទៅឯហ្នឹងទៅ!!
ដល់ហើយក៏ញ៉ុមសុំអង្គការទៅស្រុកកំនើតញ៉ុមអញ្ចឹងទៅណាស់!!បានទៅនៅតាកែវណោះវិ
ញទៅ។

កៈ ហ្ន៎!!ហ្នឹងហើយអ៊ីចឹងបានទៅនៅស្រួលណោះវិញទៅ?

ខៈចាំ!!

កៈ តែយាយពេលនៅក្នុងសង្គ្រាមហ្នឹងមានដែលឃើញមានអ្នកណាគេសម្លាប់មនុស្សអីអត់?

ខៈ ហ៊ីមិនមែនអត់ទេនាងអើយ គេហៅទាំងគ្រួសារយកទៅសម្លាប់ចោលតែម្តងទៅហ្នឹង!!

កះ ហើយយើងកំពុងតែធ្វើការធ្វើការអញ្ចឹងហោ?

ខះ យើងកំពុងតែធ្វើការធ្វើការហ្នឹងហើយខ្ញុំកាលមុននេះហ្នឹងរៀបចំចេញទៅធ្វើការ
ហោមកវិញហើយម៉ោង៤ ម៉ោង៥ព្រលប់ៗ វាចងមនុស្សស្លាបសេកហ្នឹង
ចងបណ្ដើរដើរទៅក្រោយភូមិហ្នឹងយកទៅវ៉ៃចោលបាត់ទៅ។

កះហុឺៗ!!

ខះមាន៣នាក់២នាក់អីអញ្ចឹងទៅ។

កះ វាយប់ឬក៏កណ្ដាល!!

ខះ អាថ្ងៃម៉ោង៤ ម៉ោង៥ព្រលប់ៗហ្នឹង!!

កះហ្ហ៎!!

ខះ ហើយអាថ្ងៃ ថ្ងៃដែលវៀតណាមចូលដល់យើង
ហ្នឹងហើយថ្ងៃហ្នឹងថ្ងៃដល់វៀតណាមចូលដល់តាកែវញ៉ុមដែលអាពតកាលនៅតាកែវហ្នឹង។

កះហុឺៗ!!

ខះ វៀតណាមចូលដល់តាកែវហ្នឹងថ្ងៃហ្នឹងយប់ហ្នឹង
តែគ្រួសារញ៉ុមក៏មានឈ្មោះដែរស្រួលមិនស្រួលគេយកតែប្ដីមិនដឹងគេយកទាំងអស់ក៏មិនដឹង
ទេយប់ហ្នឹង!!

កះ មានឈ្មោះថាយកទៅសម្លាប់ចោល?

ខះចាំ!!!

កះមូលហេតុអីគេយាយ?

ខះ មកពីយើងអត់អីហូបពេកតាគាត់ទៅបូតស្រូវគេហាំ!!

កះហ្ហ៎គេដឹងហោ?

ខ៖
ហ្នឹងហើយគេដឹងហើយគេនាំទៅកសាងមនុស្សហ្នឹងទៅ!!តែដូចមិនមែនថាមួយយប់ហ្នឹងទេ គេហៅយើងទៅកសាង ប៉ុន្តែគេហៅកសាងច្បាស់ជាបាត់ខ្លួនហើយ ក៏គេកសាងតែមួយគ្រួក៏មិនដឹងតែម្នាក់ក៏មិនដឹងទេ!!

ក៖ អូយភ័យណាស់យាយអើយ!!

ខ៖ ហ្នឹងហើយ ដល់ពេលដល់វៀតណាមចូលមកទៅក៏ទទួលរួចខ្លួនទៅ!!!

ក៖ ហ៊ីហោងវិញ!!

ខ៖ ហ្នឹងហើយ!!

ក៖ អូយហោងហើយចំពេលគាត់ទៅបួតច្រើនចំពេលដែលពេលអាពេលជិតបែកហ្នឹងហាំ!!!

ខ៖ ហ្នឹងហើយ!!

ក៖ ប៉ុល ពតចូលមក!!ហាវៀតណាមចូលមក!!ក៏ធូរវិញទៅ!!

ខ៖ចាំ!!

ក៖ ហ្នឹងហើយ!!អ៊ីចឹងលោកយាយតែលឺគេនិយាយតែសម្លាប់មែន ប៉ុន្តែលោកយាយដែលឃើញផ្ទាល់ភ្នែកអីអត់?

ខ៖ អត់ដែលឃើញទេ លឺសូរតែគេចាប់កូនក្មេងបោកអីក៏មិនដែលឃើញដែរ!!

ក៖ចាំ!!

ខ៖ ប៉ុន្តែមិនមែននៅស្រុកយើងទេណាស់ តែលឺសូរតគគ្នាពីណាពីណីអីអ៊ីចឹងទៅ!!

ក៖ អូយ!!យ៉ាប់ណាស់អ៊ីចឹងណោះ!!

ខ៖ តែដល់ពេលយាយដល់ពេលជំលៀសចេញពីជំនាន់ប៉ុល ពតមកវិញមានដែលឃើញរណ្តៅខ្មោចរណ្តៅអីអត់យាយ?

ខ៖ មាននៅខាងយើងនេះគេដាក់ទាំងជង្រុកហ្វាំ!!!

កៈ នៅណាវិញ?

ខៈ នៅខាងភូមិ ខាងលិចភូមិញ៉ុមហ្នឹង គេហៅកណ្ដឹង!!

កៈចាំ!!

ខៈ គេហៅស្រុកកណ្ដឹងហ្ន៎!!

កៈហ៊ឺៗ!!

ខៈជិតម្ដុំភ្នំតាម៉ៅដែរនោះ!!

កៈ ចាំគឺពេញពេញម៉ង!!គេដាក់នៅក្នុងជង្រុកឬក៏នៅក្នុងរណ្ដៅ?

ខៈ គេធ្វើជង្រុកដាក់ម៉ង
ប្រមូលហា!!ដូចថាយើងបែកមកប្រជាជនយើងប្រមូលដាក់ជង្រុកហាំ!!

កៈ ហ្ន៎ប្រមូលឆ្អឹងហោ??

ខៈ ចាំប្រមូលក្បាលក្បាលហ្នឹង!!

កៈហ្ន៎!!

ខៈ នៅក្បាលនៅឆ្អឹងអីប្រមូលដាក់ជង្រុកមួយដុំអញ្ចឹងទៅ!! ជង្រុកហ្នឹងប៉ុនផ្ទះ
ចង់ប៉ុនផ្ទះយើងដែរហ្នឹងណាស់!!

កៈហ៊ឺ!!

ខៈ កន្លែងដាក់!!

កៈ យាយចុះអ្នកដែលសំណាងដូចអត់មានហាំ
ដូចថាអាគេជិតដល់ពេលគេបែកហើយហើយហ្ន៎!!វៀតណាមមកជួយទាត់ហ្ន៎!!តែស្លាប់នោះម៉េចទៅ!!

ខៈ អាស្លាប់វារស់ប៉ុន្មានមុនមួយថ្ងៃពីរថ្ងៃអញ្ចឹងទៅ
បប្ញលគ្នាចេះតែស្លាយអញ្ចឹងទៅ!!នឹកឃើញថាអូយបើគេមកមុនតែមួយថ្ងៃពីរថ្ងៃមិនដឹង!
ប្តីគេប្រពន្ធគេដូចតែគ្នាហ្នឹង!!

កៈចាំ!!

ខៈ ចេះតែនឹកឃើញស្តាយហើយ!!

កៈ អានិតណាស់យាយអើយ!!

ខៈចាំ!!

កៈ អឺចឹងលោកយាយពេលលោកចប់បែកពីជំនាន់ប៉ុល
ពតមកលោកយាយធ្វើការអីគេវិញមកលោកយាយធ្វើការអីគេវិញ?

ខៈ អត់មានធ្វើអីផង!!នៅផ្ទះគ្រាន់តែលក់អីបន្តិចបន្តួចកាប៉េកាប៉ុកពីដើមចេះតែលក់
លក់ដូចថាលក់ស៊ុបលក់អីអញ្ចឹងទៅ!!អ់តមានធ្វើអីផង!!

កៈចាំ!!

ខៈ អាងតែតាគាត់ធ្វើការចេះតែនេះទៅ ចេះតែហូបទៅ
បានប្រាក់ខែអីពីដើមបានអីចេះតែហូបទៅ យើងបើកអង្ករបើកអីហូបអង្ករអីអញ្ចឹងទៅ!!

កៈចាំ!!

ខៈ ហូបអីទិញអីដូរតែអង្ករហ្នឹងទៅ។

កៈ ចាំ
លោកយាយសំរាប់អើរដូចរបៀបថាកូនចៅដែលលោកយាយមានហ្នឹងហាំពួកគាត់ទៅរៀនទៅ
អីខ្លះអត់?

ខៈ ទៅរៀនតើកូន ពួកអស់ហ្នឹងអីសុទ្ធតែទៅរៀន
អាហ្នឹងហើយ(កូនគាត់)រៀនជាមួយបងមីអូនឯងអីវ៉ាន់ហ្នឹងហាំ!!

កៈ ហ្នឹងហើយ!!

ខះ ហ្នឹងហើយសុទ្ធតែរៀនជាមួយគ្នាទាំងអស់ហ្នឹង!!អោយរៀនទាំងអស់ពួកហ្នឹង!!

កះ បងញ៉ុមអាផលខូចណាស់យាយហាំ!!

ខះ ហ្នឹងហើយ អាហ្នឹងរៀនជាមួយគ្នាហ្នឹងហាំ!!សុទ្ធតែដៃគូរគ្នាហ្នឹងហា!!

កះ ឥឡូវពួកម៉ាកគ្នាហើយហ្នឹងហេ?

ខះ ហ្នឹងហើយ!!

កះ ហើយផឹកជាមួយគ្នារហូតយាយហេ?

ខះ ទឹមតែជួប!!អត់ទេទឹមជួបព្រឹកមិញទេ!! ជួបគ្នាពីម្សិល
ពីម្សិលម្ងៃហ្នឹងលឺសូរនិយាយថាឯងខំហៅវា អាឌីហៅឯងសុទ្ធតែអ្នកមាន អញ្ចេក!!
ហើយតាំងពីព្រឹកម្សិញហ្នឹងទៅបានទៅជួបគ្នាបណ្តើរគ្នាមក!!

កះ ចាំចឹអឺចឹងបានអត់ឃើញបងញ៉ុមទៅលក់ នៅដេកនៅផ្ទះស្រវឹងនៅផ្ទះហ្នំ!!

ខះ លក់អីគេ?

កះ គាត់លក់ទូរសព្ទ័។

ខះ ហ្នឹងហើយអត់ឃើញទៅលក់!!

កះ ហ្នឹងហើយ!!

ខះ ថាថ្ងៃហ្នឹងមកជួយកាប់ដីដាក់រោងគោគ្រូផាននោះ!!

កះចាំ!!

ខះ ហើយដល់ពេលនេះមិនដឹងកាប់ហើយមិនហើយទេជួបអាហ្នឹងមកផឹកនេះមក!!

កះហ៊ីយ៉ាប់ណាស់!!និយាយមិនកើតទេយាយអើរ អាយុច្រើនតែអាយុមែន
ប៉ុន្តែយ៉ាប់ណាស់។អឺចឹងលោកយាយមូលហេតុអីលោកយាយដូចជាអោយកូនទៅរៀនដែល
លោកយាយ

មូលហេតុអីអោយគាត់ទៅរៀនលោកយាយ?ពេលលោកយាយបញ្ជូនគាត់ទៅសិក្សាសង្ឃឹមអីបានពីគាត់មកវិញទៅរៀនអញ្ចឹងហា៎!!យាយសង្ឃឹមម៉េចដែរពេលពួកគាត់ទៅរៀន?

ខ៖ អោយសង្ឃឹមថាអោយវាចេះដឹងទៅអោយវាបានជួយចិញ្ចឹមយើង
តែឥឡូវមិនចិញ្ចឹមទេមានតែហុចដៃមកសុំយើងអញ្ចឹងទៅ!!

ក៖ លោកយាយឥឡូវធ្វើការអីគេ?ដែលម៉េចបានគាត់សុំលុយលោកយាយបាន
ដែលលោកយាយចាស់ហើយ?

ខ៖ វាធ្វើសំនង់ !!

ក៖ហ្ហ៎!!

ខ៖ មួយថ្ងៃ៦០០០០វាជាងហា៎!!

ក៖ តែពេលគាត់ធ្វើបានគាត់អោយលោកយាយទុកហេ?

ខ៖ បានមកវាចាយតែ២ថ្ងៃទេមីនាង បានអាណាទិញ
ឃើញលុយវាអានេះម៉ែឯងទុកទៅវត្តអានេះទិញអង្ករស៊ី
តែដល់មកអាទៅវត្តក៏អត់ឃើញអាទិញអង្ករក៏អត់ឃើញមានតែសុំយើងថែម !!

ក៖ អញ្ចឹងលោកយាយដេរបានទៅសុំថែមពីយាយទៀត?

ខ៖
តិចតែមីអូនឯងមកយកខោអាវអីហុចលុយមីអូនឯងទៅបាត់ឡើងវាយកទៅវិញអស់ឥឡូវហើយ!!

ក៖ គឺបានមកគឺតែផឹកម៉ងយាយណោះ?

ខ៖ ពេលណាញ៉ុមបន់អោយតែទៅទេ តែមិនព្រមទៅសោះ ទៅធ្វើការវិញនេះ
កន្លែងធ្វើការនៅទុកចោលកន្លែងធ្វើការណោះប៉ុន្តែវាមិនព្រមទៅ!!

ក៖ ញ៉ុមដឹងថាយាយតឹងទ្រូងខ្លាំងប៉ុណ្ណាហើយ!!

ខ៖ ហ៊ីយ៉ាប់ណាស់មីអូនអើយ!!

ក៖ តែអត់អីទេសង្ឃឹមថាថ្ងៃក្រោយ!!

ខ៖ អាចៅ៥ ៦នាក់ហ្នឹង ងាប់តែមីមួយនោះអាគូរដណ្ដឹងហ្នឹងឪបមកមិញហ្នឹងនោះ!!

ក៖ចាំ!!

ខ៖ តែអាមួយនេះគ្មានជួយយើងទេ!!

ក៖ចាំ!!

ខ៖ ហ្នឹងហើយ មានតែទារលុយថែម។

ក៖អ៊ិចឹងលោកយាយដូចជាមានពាក្យពេចន៍អីផ្ដែផ្ដាំ
នេះគឺជាសំនួរមួយចុងក្រោយហើយណាស់មានពាក្យអីផ្ដែផ្ដាំកូនចៅជំនាន់ក្រោយអោយថា
អោយដើរលើផ្លូវម៉េចគេចផុតពីផ្លូវម៉េចអ៊ីចឹងហាំ!!

ក៖ថា
អោយរាល់ថ្ងៃចេះតែណែនាំវាធ្វើម៉េចថាកុំអោយអារឿងមានគ្រឿងញៀនគ្រឿងអីខំរៀនខំអី
ទៅស្រុកសម័យឥឡូវនេះអោយតែហ្អែងអោយតែខំរៀនខ្មែរតែល្មមៗក៏បានដែរណាស់
អោយតែមើលអោយតែរួចបានទៅបានខំរៀនអង់គ្លេសអង់អីទៅព្រោះសម័យឥឡូវនេះគេមាន
តែអង់គ្លេសអង់អីទេ!!ចេះតែណែនាំវា
បើវាស្ដាប់យើងក៏ស្ដាប់ទៅបើវាមិនស្ដាប់យើងមិនដឹងធ្វើម៉េចទេ!!

ក៖ ចាំ!!លោកយាយមានពាក្យអីចង់និយាយបន្ថែមទៀតពីខ្លួនឯង អូខេ
ពីពេលវេលាដែលពិបាកបំផុតក្នុងជីវិតពេលណាវិញ?

ខ៖
ហ៊ីពិបាកហ្នឹងពិបាកណាស់មីអូនតាំងពីតាទៅបួសហើយណាកូនវាឈឺផងអីផងខ្លះឈឺទៅខ្លះ
អីទៅណាអត់ផងលំបាក!!ឥឡូវហ្នឹង
រាល់ថ្ងៃហ្នឹងឥឡូវនេះរកតែ១០០ដាក់ហោរប៉ាវគ្មានផងនេះ
ម្ហូបរាល់ថ្ងៃហ្នឹងជឿរសាច់ជ្រូកគេចង់៤០០០០ ៥០០០០ហើយ!!

ក៖ ចុះកូនអីវ៉ាន់អត់ជួយចិញ្ចឹមទេចុះ!!

ខ៖ អើយម៉ែវាទឹមតែថាឆ្លងទន្លេរះផងអីផង អត់ហ៊ានទារពីគេទេ ងាប់តែមីមួយនេះ!!

ក៖ អ៊ីចឹងកូនទាំង៥នាក់យាយហេ?

ខ៖ចា៎!!

ក៖តែ!!

ខ៖គេសុទ្ធតែមានគ្រួសារអីគេអស់ហើយ
អានេះអីឪវានៅណោះផ្សេងអីមកនៅលើយើងទាំងអស់!!

ក៖ ឥឡូវយាយសង្ឃឹមអីគេនៅក្នុងជីវិត?

ខ៖ សង្ឃឹមអី មានអីមានតែចៅចិញ្ចឹមហ្នឹង។

ក៖ អញ្ចឹងសង្ឃឹមនៅលើចៅហើយហ្នឹងហេ?

ខ៖ នៅលើចៅ។

ក៖ ចា៎ហ្នឹងហើយ
អ៊ីចឹងអរគុណច្រើនលោកយាយដែលបានអោយញ៉ុមសំភាសន៍អំពីជីវប្រវត្តិរបស់លោកយាយ
ហើយអ្វីទាំងអស់កូនចៅលោកយាយនឹងបានស្តាប់អំពីជីវប្រវត្តិរបស់លោកយាយទាំងអស់សំរាប់ទៅថ្ងៃក្រោយណាស់លោកយាយ!

ខ៖ចា៎!!

ក៖អរគុណច្រើន។